ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ:...០០៤/០៨......កប/ស·ជ·ក

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០០៨

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះអង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជក នៃរោងចក្រ សហគ្រាសផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា កន្លងមកគណៈកម្មការប្រឹក្សាការងារ បានប្រជុំពិភាក្សាគ្នា ហើយបានសម្រេចធ្វើការដំឡើងប្រាក់ឈ្នួលអប្បបរមា ជូនបងប្អូនកម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងពី ចំនួន៤០ (សែសិប) ដុល្លាអាមេរិក ទៅ ៤៥ (សែសិបប្រាំ) ដុល្លាអាមេរិក ក្នុងមួយខែ សម្រាប់កម្មករ និយោជិតសាកល្បង និងពី ៤៥ (សែសិបប្រាំ) ដុល្លា អាមេរិក ទៅ ៥០ (ហាសិបដុល្លា) អាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ ដោយអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១០ ទើបធ្វើការពិភាក្សាគ្នាសារជាថ្មី។

ផ្ទុយមកវិញ ថ្មីៗនេះ មានសហជីពមួយចំនួនបានធ្វើការទាមទារឱ្យធ្វើការដំឡើងប្រាក់ឈ្នួលអប្បរមាជូនបងប្អូនកម្មករនិយោជិតនៃរោងចក្រសហគ្រាសផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងឡើងវិញ។ ផ្អែកតាមច្បាប់ស្តីពីការងារ ការកំណត់ប្រាក់ឈ្នួលអប្បបរមា គឺត្រូវមានការផ្តល់យោបល់ពីគណៈកម្មការប្រឹក្សាការងារជាមុនសិនដូចដែលគណៈកម្មការនេះបានធ្វើកន្លងមកចំនួនពីរលើករួចមកហើយ គឺនៅឆ្នាំ២០០០ និង នៅឆ្នាំ២០០៦។ ដូចនេះ បងប្អូនសហជីពត្រូវលើកសំណើទាមទារនេះដាក់ជូនគណៈកម្មការប្រឹក្សាការងារ ដែលជាយន្តការត្រីភាគីចែងដោយច្បាប់ស្តីពីការងារ តាមរយៈសមាជិកគណៈកម្មការប្រឹក្សាការងារតំណាងកម្មករនិយោជិត ដើម្បីប្រជុំពិភាក្សាគ្នាពិនិត្យ និងសំរេចតាមនីតិវិធីច្បាប់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានសង្ឃឹមយ៉ាងមុតមាំ ថាអង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និង និយោជក នៃរោងចក្រ សហគ្រាសផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា នឹងខិតខំអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ជាក់ជាមិនខាន។ករណី

អនុវត្តមិនស្របតាមនីតិវិធី នៃច្បាប់បងប្អូននឹងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ថង សុខ**

ចម្លងជូន ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- គ្រប់បណ្តាញទូរទស្សន៍ និងវិទ្យុ ដើម្បីផ្សព្វផ្សាយ"
- អគ្គនាយកដ្ឋានការងារ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង
- គ្រប់សហព័ន្ធសហជីព
- គ្រប់សមាគមនិយោជក

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ
- ក្រសួងមហាផ្ទៃ

"ដើម្បីជ្រាប"

- នាយកដ្ឋានវិវាទការងារ